# បច្ចុប្បន្នកាល

អែលឌើរ ឡែនស៍ ប៊ី វីកមែន
នៃពួក 70 នាក់

*បានផ្តល់ដល់យើងឱ្យមានជីវិតនៅសព្វថ្ងៃនេះ ដែលយើងបានអះអាងអំពីព្រះគុណលាងសំអាតរបស់ដង្វាយធួន យើងនឹងរស់នៅជារៀងរហូតជាមួយនឹងព្រះ ។*

កាលពីបីសប្តាហ៍កន្លងទៅ ខ្ញុំបានបោះជំហានដើរចូលទៅក្នុងអតីតកាល ។ រំពេចនោះ ខ្ញុំបានរកឃើញបច្ចុប្បន្នកាលជាថ្មី ។ ហើយអំពីបច្ចុប្បន្នកាលនេះដែលខ្ញុំចង់និយាយ ។

ការចាត់តាំងរបស់សាសនាចក្រមួយបាននាំឱ្យខ្ញុំធ្វើដំណើរលើចម្ងាយផ្លូវដ៏វែងឆ្ងាយប៉ាស៊ីហ្វិក ទៅកាន់ដែនដីនៃប្រទេសវៀតណាម ។ ចំពោះខ្ញុំ ការធ្វើដំណើរនេះគឺច្រើនជាងការរហោះហើរឆ្លងកាត់មហាសមុទ្រទៅទៀត ។ វាគឺជាការបោះជំហានត្រឡប់ចូលទៅក្នុងអតីតកាល ។ អស់រយៈពេលជាង 40 ឆ្នាំកន្លងទៅ ខ្ញុំបានបំរើនៅក្នុងសមរភូមិ នៃទឹកដីនោះជានាយទាហានថ្មើរជើងមួយរូប ។ ដោយបានធ្វើអន្តរាគមន៍អស់ជាច្រើនទស្សវត្ស អនុស្សាវរីយនៃទីកន្លែងនោះ ប្រជាជននៅទីនោះ និងក្រុមទាហានរបស់ខ្ញុំជាអ្នកដែលខ្ញុំបានបំរើការជាមួយបានជឹតជាប់នៅក្នុងគំនិតរបស់ខ្ញុំ ។ មានពេលមួយយ៉ាកុបបានសរសេរថា "ជីវិតយើងក៏រសាត់ហួសទៅហាក់ដូចជាការយល់សប្តិចំពោះយើង..." (យ៉ាកុប 7:26) ។ រឿងនេះកើតឡើងចំពោះខ្ញុំ ។ ឥឡូវនេះខ្ញុំបានត្រឡប់មកវិញពីការចងចាំរបស់ខ្ញុំចំពោះទីកន្លែងនោះ បន្ទាប់ពីរយៈពេលជិតពាក់កណ្តាលសតវត្ស ។ ការងារសាសនាចក្ររបស់ខ្ញុំត្រូវបានបញ្ចប់ ខ្ញុំបានប្តេជ្ញាចិត្តថានឹងទៅលេងតំបន់សមរភូមិនោះម្តងទៀត ។ ដោយព្រមជាមួយនឹងភរិយាជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំបានធ្វើធម្មយាត្រាទៅកាន់កន្លែងមួយដែលមានសារៈសំខាន់ ។

ខ្ញុំមិនច្បាស់ថាខ្ញុំនឹងរកឃើញអ្វីនោះទេ បន្ទាប់ពីរយៈពេលអស់ជាច្រើនឆ្នាំនោះ ។ អ្វីដែលខ្ញុំរកឃើញគឺវាមិនគួរឱ្យជឿសោះ ។ ជំនួសឱ្យក្រុមមនុស្សដែលរងទុក្ខដោយសង្គ្រាម ខ្ញុំបានឃើញប្រជាជនប្រកបដោយភាពក្លាហាន ហើយនៅក្មេង ។ ជំនួសឱ្យជនបទដែលត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម ខ្ញុំបានរកឃើញនូវទីវាលបៃតង ដែលប្រកបដោយសេចក្តីសុខសាន្ត ។ សូម្បីតែព្រៃល្បាតក៏ដុះថ្មីដែរ ។ ខ្ញុំគិតស្មានថាខ្ញុំបានរំពឹងទុកតែពាក់កណ្តាលទេ ដែលថានឹងបានឃើញអ្វីដែលនៅកាលពីអតីត ប៉ុន្តែខ្ញុំបែរជារកឃើញបច្ចុប្បន្នកាល និងការសន្យានៃភាពភ្លឺថ្លានៅអនាគតកាលទៅវិញ ។ ខ្ញុំត្រូវបានរំលឹកថា "ទឹកភ្នែកនឹងមាននៅជាប់អស់មួយយប់ក៏បាន តែព្រឹកឡើងគង់នឹងមានសេចក្តីអំណរឡើងដែរ" (ទំនុកដំកើង 30:5) ។

នៅពេលខ្ញុំដាក់ជើងជាន់ទឹកដីសមរភូមិនោះ ហើយដើរតាមផ្លូវដែលកាន់តែមានព្រៃល្បាតនោះម្តងទៀត នៅក្នុងចិត្តរបស់ខ្ញុំ ខ្ញុំបានឮសំលេងនៃកាំភ្លើងយន្ត សំលេងនៃគ្រាប់កាំភ្លើង និងសំលេងកាំភ្លើងតូចម្តងទៀត ។ ខ្ញុំបានមើលឃើញម្តងទៀតនូវផ្ទៃមុខសម្បុរពណ៌ត្នោតរបស់មិត្តភក្តិកាលពីយុវវ័យដែល "បានប្រគល់ជីវិតពួកគេ ដើម្បីជាសញ្ញានៃការលះបង់"(Abramham Lincoln, Gettysburg Address) ។ ហើយខ្ញុំបានគិតអំពីមិត្តម្នាក់ជាពិសេស នៅថ្ងៃមួយ ដែលជាថ្ងៃតែមួយគត់--- ជាថ្ងៃទី 3 ខែ មេសា ឆ្នាំ 1966 ។ ជាថ្ងៃអាទិត្យមុនបុណ្យអ៊ីស្ទើរ--- ។ រដូវបុណ្យ

អ៊ីស្ទើរស្ទើរតែមានរយៈពេល--- 42 ឆ្នាំកន្លងទៅហើយមកដល់ថ្ងៃនេះ។

ក្រុមកងទ័ពថ្មើរជើងរបស់យើងបានចូលក្នុងប្រទេសវៀតណាមអស់រយៈពេលជាច្រើនខែ។ ខ្ញុំជាមន្ត្រីយោធាម្នាក់ ជាអ្នកដឹកនាំនៃកងកាំភ្លើងអនុសេនាតូច។ យើងត្រូវបានស្ថិតនៅក្នុងប្រតិបត្តិការសង្គ្រាមស្ទើរតែមិនដកដៃរួច។ ពេលនោះកងទ័ពរបស់យើងបានចាប់ផ្ដើមចូលទៅជ្រៅក្នុងដែនដីរបស់សត្រូវ។ ពីព្រលឹមស្រាង១ យើងបានបញ្ជូនកងឈ្លបយកការណ៍យាមល្បាតប្រហែលជា 10 នាក់។ នៅក្នុងកងទ័ពនោះមានយុទ្ធជនម្នាក់គឺជាពលបាលត្រី អ័រធើរ ម័រិស។ មានយុទ្ធជនមួយចំនួនត្រូវរងរបួសនៅក្នុងការប្រយុទ្ធ រួមទាំងពលបាលត្រី ម័រិស ដែលរងរបួសបន្តិចបន្តួចលើស្បែក។ ទីបំផុតកងយុទ្ធជនយាមល្បាតបានត្រឡប់មកកាន់ខ្សែត្រៀមរបស់យើងវិញ។

យើងបានហៅវិទ្យុទាក់ទងសុំឱ្យឧទ្ធម្ភាគចក្រខាងវេជ្ជសាស្ត្រមក។ ដោយលើកដាក់យុទ្ធជនរបួសទាំងនោះទៅលើឥទ្ធម្ភាគចក្រ ខ្ញុំបានជំរុញពលបាលត្រី ម័រិស ឱ្យឡើងទៅផងដែរ។ គាត់ស្ទាក់ស្ទើរ។ ខ្ញុំបានជំរុញគាត់ម្ដងទៀត។ គាត់នៅតែស្ទាក់ស្ទើរ។ ខ្ញុំបានដាក់តឿនគាត់ជាថ្មីម្ដងទៀត។ គាត់បដិសេធម្ដងទៀត។ ទីបំផុត ខ្ញុំបាននិយាយថា "ពលបាលត្រី ម័រិស ឡើងទៅលើឧទ្ធម្ភាគចក្រនោះទៅ"។

គាត់មើលមកខ្ញុំ ជាមួយកែវភ្នែកដ៏ស្មោះត្រង់របស់គាត់ ដោយអង្វរថា--- "លោក ខ្ញុំសូមអង្វរ"--- រួចហើយមានពាក្យទាំងនេះនៅលងជាប់នឹងខ្ញុំជានិច្ចថា *"ពួកគេមិនអាចសំលាប់យុទ្ធជនរឹងមាំដូចខ្ញុំនេះបានទេ"*។

ទិដ្ឋភាពទាំងមូលត្រូវបានដិតជាប់នៅក្នុងចិត្តខ្ញុំ ដូចជារូបភាពក្នុងសមរភូមិមួយៈ ការឆ្លាព្រៃល្បាត ភាពមិនអត់ធ្មត់ ស្លឹស្លាបចក្រនៃឧទ្ធម្ភាគចក្រសួរវន្ទឹក អ្នកបើកយន្តហោះបានមើលមកខ្ញុំដោយស្ទាក់ស្ទើរ ហើយមិត្តរបស់ខ្ញុំនៅអង្វរសុំនៅជាមួយនឹងកងទាហានគាត់។ ខ្ញុំបានទន់ចិត្ត។ ខ្ញុំបានលើកដៃលាទៅអ្នកកាប់ឆ្កា សំរាប់ឱកាសដើម្បីរស់នៅមួយថ្ងៃទៀត។ មុនពេលព្រះអាទិត្យលិចនៅថ្ងៃនោះ មិត្តជាទីស្រឡាញ់របស់ខ្ញុំ---ពលបាលត្រី អ័រធើរ សាយ៉ាស់ ម័រិស បានដេកស្លាប់នៅលើដីដែលត្រូវបានសំលាប់ដោយភ្លើងរបស់សត្រូវ។ នៅក្នុងចិត្តរបស់ខ្ញុំនៅឮសំលេងខ្ទរម្ដងហើយម្ដងទៀតខ្ញុំឮការប្រកាសរបស់គាត់--- "ពួកគេមិនអាចសំលាប់ ពួកគេមិនអាចសំលាប់ ពួកគេមិនអាចសំលាប់..."។

ប្រាកដណាស់ នៅក្នុងការយល់ដឹងមួយ គាត់បានធ្វើខុសគួរឱ្យខ្លាច។ ជីវិតរមែងស្លាប់គឺងាយពុកផុយណាស់។ មានតែសង្ខាក់បេះដូងមួយប៉ុណ្ណោះ ការឈប់ដកដង្ហើមតែមួយដង្ហើមញែកពិភពលោកនេះចេញពីពិភពបន្ទាប់ទៀត។ នៅគ្រាមួយមិត្តរបស់ខ្ញុំគឺជាមនុស្សរស់ខាន់ ហើយនៅរស់បន្ទាប់មកវិញ្ញាណអមតភាពរបស់គាត់ បានចាកចេញទុកចោលរូបកាយរបស់គាត់ នូវដុំមួយនៃរូបកាយគ្មានជីវិត។ សេចក្ដីស្លាប់គឺជារាំងននមួយដែលមនុស្សម្នាក់១ ត្រូវតែឆ្លងកាត់ដូចជាពលបាលត្រី អ័រធើរ ម័រិស---គ្មាននរណាម្នាក់ក្នុងចំណោមយើង ដឹងថាពេលណាវានឹងកើតឡើងនោះទេ។ នៅគ្រប់ទាំងឧបសគ្គ ដែលយើងប្រទះ ឧសគ្គដ៏ធំជាងគេបំផុតប្រហែលជា*ការយល់ខុសថាជីវិតរមែងស្លាប់គឺនៅជានិរន្ត* និងលទ្ធផលរបស់វា---ដែលយើងអាចផ្អាករហូតដល់ថ្ងៃស្អែកក្នុងការស្វែងរក និងផ្ដល់នូវការអភ័យទោស នៅក្នុងចំណោមគោលបំណងចំបងនៃជីវិតរមែងស្លាប់ ដូចដែលដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទបង្រៀន។

សេចក្ដីពិតដ៏អស្ចារ្យនេះត្រូវបានបង្រៀនដោយអាមូលេកនៅក្នុងព្រះគម្ពីរមរមនថាៈ

"ត្បិតមើលចុះ ជីវិតនេះគឺជាពេលវេលាសំរាប់ឱ្យមនុស្សប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ មែនហើយមើលចុះ *ពេលវេលានៃជីវិតនេះ* គឺជាពេលវេលាសំរាប់ឱ្យមនុស្សប្រព្រឹត្តការងារទាំងឡាយរបស់ខ្លួន។

"... ហេតុដូច្នោះហើយ ខ្ញុំសូមអង្វរដល់អ្នកថា ចូរអ្នករាល់គ្នាកុំបង្អង់នូវពេលវេលាចំពោះការប្រែចិត្តទុកដល់ទីអវសាន្ត នោះឡើយ...។

"...ព្រោះវិញ្ញាណដែលជាម្ចាស់រូបកាយរបស់អ្នក កាលអ្នករាល់គ្នាចេញពីជីវិតនេះហើយ គឺជាវិញ្ញាណដដែលនោះ នឹងមានអំណាចធ្វើជាម្ចាស់រូបកាយរបស់អ្នក នៅក្នុងស្ថានដ៏នៅអស់កល្បជានិច្ចនោះដែរ" (អាលម៉ា 34:32--34 មានបន្ថែមការសង្កត់ន័យ)។

នោះគឺជាការបង្ហាញដ៏រឹងមាំមួយ ដែលអាមូលេកប្រើ--- "*ពេលវេលា* នៃជីវិតនេះ!" សាវកយ៉ាកុប បាននិយាយរបៀបនេះថា: "អ្នករាល់គ្នាមិនដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ? ត្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ ដែលឃើញតែមួយភ្លែតរួចបាត់ទៅ" (យ៉ាកុប 4:14)។ ហើយបើមនុស្សយើងយ៉ាងម៉េច នោះពេលយើងស្លាប់ទៅពីជីវិតនេះ យើងនឹងជាមនុស្សយ៉ាងនោះដែរ នៅពេលយើងចូលដល់ជីវិតបន្ទាប់នោះ។ មានអំណរគុណណាស់ យើងមានថ្ងៃនេះ។

ប្រសិនបើពលបាលត្រី ម័ររិស មានកំហុសពិតមែន នោះគាត់ក៏បានធ្វើត្រូវប្រកបដោយកិត្តិគុណផងដែរ! យើងពិតជានឹងមិនចេះស្លាប់ នៅក្នុងការយល់ដឹងដែលថាដង្វាយធួនរបស់ព្រះគ្រីស្ទ បានយកឈ្នះលើសេចក្តីស្លាប់ ទាំងខាងរូបកាយ និងខាងវិញ្ញាណ។ ហើយ *បានផ្តល់ដល់* យើងឱ្យមានជីវិតនៅ *សព្វថ្ងៃនេះ* ដែលយើងបានអះអាងអំពីព្រះគុណលាងសំអាតរបស់ដង្វាយធួន យើងនឹងរស់នៅជារៀងរហូតជាមួយនឹងព្រះ។ ជីវិតនេះមិនមានពេលច្រើនសំរាប់ទទួលយក និងប្រមូលយកដូចជាវាគឺជាពេលសំរាប់ផ្តល់ឱ្យ និងរីកចំរើននោះទេ។ ជីវិតរមែងស្លាប់គឺជាសមរភូមិ ដែលយុត្តិធមិ និងសេចក្តីមេត្តាករុណាត្រូវតែជួបគ្នា។ ប៉ុន្តែយុត្តិធមិ និងសេចក្តីមេត្តាករុណាមិនមែនជួបគ្នាដូចជាសត្រូវទេ ពីព្រោះយុត្តិធមិ និងសេចក្តីមេត្តាករុណា ត្រូវបានផ្សះផ្សានៅក្នុងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ចំពោះមនុស្សទាំងអស់ដែលប្រើប្រាស់ថ្ងៃនេះដោយវៃឆ្លាត។

វានៅតែមានសំរាប់អ្នក និងខ្ញុំ ទាំងការ *ស្វែងរក* និងផ្តល់ការអត់ទោសនោះ--- ទាំងការប្រែចិត្ត និងការសន្ទឹងនូវសេចក្តីសប្បុរសចំពោះអ្នកដទៃ--- ដែលអាចឱ្យយើងឆ្លងកាត់ច្រកទ្វារ ដែលព្រះអង្គសង្គ្រោះបើកឱ្យ ដើម្បីឆ្លងកាត់ផ្លូវពីជីវិតនេះចូលក្នុងភាពរុងរឿង។ *ថ្ងៃនេះ* គឺជាថ្ងៃសំរាប់អភ័យទោសដល់អ្នកដទៃនូវ "ការរំលង" របស់ពួកគេមានសុវត្ថិភាពនៅក្នុងចំណេះដឹងដែលព្រះអម្ចាស់ នឹងអភ័យទោសដល់យើងដូចគ្នា។ ដូចជាអ្វីដែលលូកាបានកត់ត្រាទុកយ៉ាងសំខាន់ថា "ចូរអ្នករាល់គ្នាមាន*ចិត្តមេត្តាករុណា* " (លូកា 6:36 មានបន្ថែមការសង្កត់ន័យ)។ ភាពឥតខ្ចោះអាចបង្វែរយើងនៅទីនេះ ប៉ុន្តែយើងអាចមានចិត្តមេត្តាករុណា។ ហើយនៅទីបញ្ចប់ ការប្រែចិត្ត និងការអភ័យទោសគឺមាននៅក្នុងតំរូវការជាចំបងរបស់ព្រះពីយើងរាល់គ្នា។

ការធ្វើដំណើររបស់ខ្ញុំត្រឡប់មកដល់ពេលបញ្ចប់ ខ្ញុំមើលជុំវិញទៅទីវាលដ៏សុខសាន្តទាំងនោះ នៅថ្ងៃនេះ ហើយមើលឃើញនូវផលរបស់វានូវការសន្យានៃថ្ងៃស្អែក។ ខ្ញុំបានគិតអំពីមិត្តរបស់ខ្ញុំ ពលបាលត្រី អ័រធើរ សាយវ៉ាស់ ម័ររិស។ ខ្ញុំបានគិតអំពីទំនុកដំកើងនៃវាសនានៅថ្ងៃអាទិត្យនៅថ្ងៃស្អែកនោះ។ ហើយខ្ញុំមានអំណរគុណជាពន្លឹកចំពោះព្រះប្រោសលោះ នៃព្រឹកថ្ងៃអីស្ទើរ ដែលបានផ្តល់ជីវិតដល់យើង ដែលបានយាងចុះក្រោមគ្រប់ទាំងអស់ ធ្វើឱ្យយើងអាចងើបឡើងលើហួសអ្វីៗទាំងអស់---នៅថ្ងៃស្អែក បើយើងដណ្តើមយកបានថ្ងៃនេះ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។